**Declassified to Public**
**25 January 2019**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទ:** ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៨

**ពី:** **Isaac Endeley** ប្រធានអង្គភាពគាំពារការការពារក្តី

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់នៃសំណុំរឿង ០០២

**កម្មវត្ថុ:** ឋានៈរបស់សហមេធាវីអន្តរជាតិ ក្នុងសំណុំរឿង ០០២/០២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Mar-2018, 15:43
CMS/CFO: Sann Rada

១. បន្ទាប់ពីទទួលបានអនុស្សរណៈរបស់លោកចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៨ [ឯកសារ E378/8] រួចមក ខ្ញុំមានកិត្តិយសជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងឲ្យបានជ្រាបថា តាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ ខ្ញុំបានសរសេរលិខិតទៅលោក Victor Koppe នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៨ ស្នើសុំការបំភ្លឺពាក់ព័ន្ធនឹងឋានៈសមាជិកភាពរបស់គាត់នៅក្នុងគណៈមេធាវីក្រៅប្រទេសកម្ពុជា។ លោក Victor Koppe បានឆ្លើយតបនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨ ហើយខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃចម្លើយតបរបស់គាត់។

- នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧ លោក Koppe បានជួបលោក នួន ជា ជាលើកដំបូងនៅមន្ទីរឃុំឃាំង អ.វ.ត.ក ហើយនៅពេលនោះ លោក នួន ជា បានស្នើសុំជាផ្លូវការឲ្យលោក Koppe តំណាងឲ្យគាត់ក្នុងនាមជាមេធាវីអន្តរជាតិនៅចំពោះមុខ អ.វ.ត.ក។

- នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានណែនាំដល់លោក Koppe ថា គាត់ពុំមានសិទ្ធិធ្វើជាតំណាងឱ្យលោក នួន ជា នៅក្នុងតួនាទីណាមួយឡើយ ប្រសិនបើគាត់ មិនបានស្បថចូលជាសមាជិកគណៈមេធាវីកម្ពុជា ជាមុនទេនោះ។ លោក Koppe បានទទួលការជូនដំណឹងថា ដោយសារតែ អ.វ.ត.ក គឺជាតុលាការក្នុងស្រុកដំបូងបង្អស់នោះ សមាជិកភាពរបស់គាត់នៅក្នុងគណៈមេធាវីកម្ពុជា គឺជា*លក្ខខណ្ឌដ៏សំខាន់បំផុតមួយមិនអាចខ្វះបាន* ដើម្បីធ្វើជាតំណាងស្របច្បាប់ឱ្យលោក នួន ជា។ នៅពេលនោះ លោក Koppe ក៏ទទួលបានការណែនាំយ៉ាងច្បាស់ផងដែរពីប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាថា បទពិសោធន៍រយៈពេល ១៨ ឆ្នាំ របស់គាត់ជាមេធាវីជនជាតិហូឡង់នោះ គឺមិនពាក់ព័ន្ធឡើយ ហើយថា មានតែការចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះដែលអាចឱ្យគាត់ធ្វើជាតំណាងផ្លូវការឱ្យលោក នួន ជា បាន។

- តាមពិត សវនាការបឋមស្តីពីការឃុំខ្លួនបណ្តោះអាសន្នចំពោះលោក នួន ជា ត្រូវបានពន្យារពេលរហូតដល់ក្រោយពេលលោក Koppe បានស្បថ និងបានចុះបញ្ជីជាផ្លូវការនៅគណៈមេធាវីកម្ពុជា។

- រយៈពេលដប់ឆ្នាំដែលបានកន្លងផុតទៅនោះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាពុំដែលបានស្នើសុំឱ្យលោក Koppe បង្ហាញនូវភស្តុតាងណាមួយថាគាត់នៅតែជាសមាជិកនៃគណៈមេធាវីបរទេសនោះឡើយ។ លោក Koppe ក៏ពុំដែលទទួលបានការណែនាំឡើយថា ការបន្តសមាជិកភាពនៅគណៈមេធាវីបរទេសគឺជាបុរេលក្ខខណ្ឌសម្រាប់ការបន្តសមាជិកភាពនៅគណៈមេធាវីកម្ពុជានោះ។ ចំណុចនេះ គាត់យល់ឃើញថា សមាជិកភាពរបស់គាត់នៅគណៈមេធាវីបរទេសគឺមិនពាក់ព័ន្ធទាល់តែសោះទៅនឹងគណៈមេធាវីកម្ពុជា លើកលែងតែនៅពេលចុះបញ្ជីទទួលស្គាល់ដំបូងនោះ។

- លើសពីនេះទៀត លោក Koppe បញ្ជាក់ថា កិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់ដែលគាត់បានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិនោះ មិនបានចែងថា គាត់ចាំបាច់ត្រូវតែនៅជាសមាជិកនៃគណៈមេធាវីបរទេស បន្ទាប់ពីចុះបញ្ជីនៅគណៈមេធាវីកម្ពុជានោះឡើយ។ គាត់ជំទាស់ថា វាគ្រាន់តែជាបុរេលក្ខខណ្ឌប៉ុណ្ណោះសម្រាប់ចុះឈ្មោះដំបូងក្នុងបញ្ជីឈ្មោះមេធាវីបរទេសនៅអង្គភាពគាំពារការការពារក្តី ("អ.គ.ក")។ លោក Koppe បញ្ជាក់ថា នៅក្នុងរយៈពេលដប់ឆ្នាំកន្លងទៅ គាត់មិនដែលទទួលបានសំណើពី អ.គ.ក ឱ្យបង្ហាញភស្តុតាងអំពីសមាជិកភាពនៅគណៈ

មេធាវីទីក្រុងអាំស្ទែដាំឡើយ។ គាត់ជំទាស់ថា ចំណុចនេះគឺអនុលោមទៅតាមការអនុវត្តនៅតុលាការអន្តរជាតិនានា ដូចជា តុលាការ ICTY និងតុលាការ ICTR ដែលនៅតុលាការទាំងនោះ សមាជិកភាពនៃគណៈមេធាវីមួយមិនមែនជាលក្ខខណ្ឌតម្រូវផ្លូវការសម្រាប់ការចុះឈ្មោះក្នុងបញ្ជីឈ្មោះមេធាវី ឬសាស្ត្រាចារ្យផ្នែកច្បាប់ឡើយ ឬក៏ថា អតីតចៅក្រមអាចធ្វើជាតំណាងស្របច្បាប់ឱ្យជនជាប់ចោទបាន។

- លោក Koppe ក៏បានបញ្ជាក់ផងដែរថា នៅពេលគាត់ចាប់ផ្ដើមធ្វើជាតំណាងពេញម៉ោងឱ្យលោក នួន ជា នៅក្នុងខែ មករា ឆ្នាំ ២០១៣ នោះ គាត់ពីដំបូងនៅមានការិយាល័យមេធាវីរបស់គាត់នៅក្នុងទីក្រុងអាំស្ទែដាំនៅឡើយទេ ពីព្រោះនៅពេលនោះ *តាមការយល់ឃើញជាទូទៅ* គឺនឹងមានការជំនុំជម្រះតែមួយប៉ុណ្ណោះនៅក្នុងសំណុំរឿង ០០២។ ទោះបីយ៉ាងណាក៏ដោយ ក្រោយមកទៀត នៅពេលដឹងច្បាស់ថា នឹងមានការជំនុំជម្រះលើកទីពីរ (ក្រៅពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមដំបូង) គាត់បានលះបង់ការប្រកបវិជ្ជាជីវៈច្បាប់របស់គាត់នៅទីក្រុងអាំស្ទែដាំ និងបានស្នើសុំជាផ្លូវការតាមរយៈលិខិតចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣ ឱ្យគណៈមេធាវីទីក្រុងអាំស្ទែដាំអនុញ្ញាតឱ្យគាត់រក្សាទុកការិយាល័យនៅក្នុងទីក្រុងភ្នំពេញតែមួយបានហើយ។ គណៈមេធាវីទីក្រុងអាំស្ទែដាំ បានផ្ដល់ការអនុញ្ញាតពិសេសឱ្យគាត់សម្រាប់រយៈពេលពីរឆ្នាំ ដោយចាប់ផ្ដើមពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥។ ក្រោយមកទៀត នៅពេលគណៈមេធាវីទីក្រុងអាំស្ទែដាំ បានណែនាំដល់លោក Koppe ថា គាត់ត្រូវបំពេញលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលបន្ថែមទៀតដើម្បីអាចឱ្យគាត់រក្សាទុកការិយាល័យនៅក្នុងទីក្រុងភ្នំពេញសម្រាប់រយៈពេលពីរឆ្នាំទៀតនោះ គាត់ក៏បានសម្រេចបញ្ចប់សមាជិកភាពរបស់គាត់នៅគណៈមេធាវីទីក្រុងអាំស្ទែដាំ ខណៈដែលគាត់កំពុងបន្តធ្វើជាមេធាវីនៅចំពោះមុខ អ.វ.ត.ក។ គាត់បានជូនដំណឹងទៅគណៈមេធាវីទីក្រុងអាំស្ទែដាំ តាមរយៈលិខិតចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៥ អំពីការសម្រេចចិត្តរបស់គាត់នេះ ហើយសមាជិកភាពរបស់គាត់បានបញ្ចប់ជាស្វ័យប្រវត្តិនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦។

- ចុងក្រោយ លោក Koppe អះអាងថា ជានិច្ចកាលគាត់បានរក្សាសមាជិកភាពរបស់គាត់នៅគណៈមេធាវីកម្ពុជា ហើយថា ប្រការនេះហើយធ្វើឱ្យគាត់មានសិទ្ធិស្របច្បាប់បន្តធ្វើជាតំណាងឱ្យលោក នួន ជា នៅចំពោះមុខ អ.វ.ត.ក។ ទោះបីយ៉ាងណាក៏ដោយ គាត់បន្ថែមថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីពិគ្រោះយោបល់ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង អ.គ.ករួចមក សម្រេចថា គាត់ចាំបាច់ត្រូវតែជាសមាជិកនៃគណៈមេធាវីបរទេស ដើម្បីអាចឱ្យគាត់បន្ត

បំពេញការងារនៅ អ.វ.ត.ក បាននោះ គាត់នឹងស្នើសុំបន្តសមាជិកភាពថ្មីឡើងវិញពីគណៈមេធាវីប្រទេសហូឡង់។ គាត់បញ្ជាក់ថា គាត់នៅតែបំពេញនូវលក្ខខណ្ឌតម្រូវចាំបាច់ទាំងអស់ដើម្បីឱ្យមានការចុះឈ្មោះទទួលស្គាល់ឱ្យបានឆាប់រហ័ស។ គាត់ក៏ជំទាស់ផងដែរថា នៅក្នុងសេណារីយ៉ូបែបនេះ កិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់របស់គាត់ជាមួយអង្គការសហប្រជាជាតិ ក៏ត្រូវធ្វើការកែប្រែទៅតាមនេះផងដែរ ដោយសារតែវាជាក្របខណ្ឌគតិយុត្តិចម្បងដែលគាត់ត្រូវប្រតិបត្តិតាម។

២. ពាក់ព័ន្ធនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងថា ខ្ញុំគួរតែជម្រាបជូនអង្គជំនុំជម្រះ "អំពីចំណាត់ការណាខ្លះដែល អ.គ.ក អាចធ្វើឡើង ដោយសារតែស្ថានភាពបែបនេះនោះ" ខ្ញុំកត់សម្គាល់ថា អនុលោមតាមវិធាន ១១ គ) ii) និង ១១ ឃ) ii) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អ.គ.ក ត្រូវបានតម្រូវឱ្យរក្សាបញ្ជីឈ្មោះ "មេធាវីបរទេសដែលទទួលការអនុញ្ញាតដោយគណៈមេធាវីរបស់រដ្ឋណាមួយដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា"។ លើសពីនេះទៀត អនុលោមតាមវិធាន ៤ គ) i) នៃវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិ ២.២ i. នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តីចែងថា ដើម្បីអាចឱ្យមេធាវីបរទេសមានសិទ្ធិបញ្ចូលទៅក្នុងបញ្ជីឈ្មោះមេធាវីរបស់ UNAKRT ដើម្បីមានសិទ្ធិធ្វើជាតំណាងឱ្យចុងចម្លើយក្រីក្រនៅចំពោះមុខ អ.វ.ត.ក បាន មេធាវីរូបនោះ "បច្ចុប្បន្នត្រូវជាមេធាវីដែលមិនបានប្រព្រឹត្តខុសនឹងវិន័យវិជ្ជាជីវៈ ហើយជាសមាជិកនៃគណៈមេធាវីដែលត្រូវបានទទួលស្គាល់នៅរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ" ក្រៅពីប្រទេសកម្ពុជា។

៣. ការអនុវត្តជាទូទៅ រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ គឺ អ.គ.ក ពិនិត្យពិច័យទៅលើសមាជិកភាពមេធាវីបរទេសនៃគណៈមេធាវីជាតិនៅក្រៅប្រទេសកម្ពុជា មុនពេលចុះឈ្មោះមេធាវីរូបនោះក្នុងបញ្ជីឈ្មោះមេធាវី។ បន្ទាប់មក ការបង្ហាញភ័ស្តុតាងអំពីសមាជិកភាពត្រូវបានបញ្ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មុនពេលទទួលចុះឈ្មោះមេធាវីដែលបានដាក់ពាក្យសុំនោះនៅគណៈមេធាវីកម្ពុជា។ ម្យ៉ាងវិញទៀត ការបង្ហាញភ័ស្តុតាងអំពីសមាជិកភាពនៅគណៈមេធាវីបរទេស គឺតម្រូវតែនៅពេលមានសំណើសុំឱ្យចុះឈ្មោះក្នុងបញ្ជីឈ្មោះមេធាវីរបស់ អ.គ.ក និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ប៉ុន្តែក្រោយមកទៀតនោះ មិនតម្រូវបែបនេះទេ។ ពុំមានមេធាវីបរទេសណាម្នាក់ដែលកំពុងប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក តម្រូវឱ្យផ្តល់នូវភ័ស្តុតាងបញ្ជាក់ពីសមាជិកភាពនៅក្នុងគណៈមេធាវីជាតិនៅក្រៅប្រទេសកម្ពុជា *ក្រោយពី*

មានការចុះឈ្មោះក្នុងបញ្ជីឈ្មោះមេធាវីរបស់ អ.គ.ក និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានោះឡើយ។

៤. លោក Koppe បានចង្អុលបង្ហាញថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា គាត់ចាំបាច់ត្រូវរក្សាសមាជិកភាពនៅគណៈមេធាវីបរទេស ព្រមទាំងសមាជិកភាពនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចឱ្យគាត់បន្តការពារក្តីនៅ អ.វ.ត.ក បាននោះ គាត់សុខចិត្តបន្តសមាជិកភាពរបស់គាត់ជាថ្មីឡើងវិញនៅគណៈមេធាវីប្រទេសហូឡង់ឱ្យបានឆាប់រហ័ស។ ក៏ប៉ុន្តែប្រសិនបើដូច្នេះមែន លក្ខខណ្ឌបែបនេះមិនត្រូវយកមកអនុវត្តចំពោះតែលោក Koppe ប៉ុណ្ណោះទេ ត្រូវយកមកអនុវត្តចំពោះមេធាវីបរទេសទាំងអស់ដែលទទួលបានការអនុញ្ញាតឱ្យការពារក្តីនៅចំពោះមុខ អ.វ.ត.ក។ វាក៏អាចតម្រូវផងដែរឱ្យធ្វើការកែប្រែទៅលើបទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុង បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី និងកិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់ដែលមេធាវីការពារក្តីបានចុះហត្ថលេខា ដើម្បីជាលក្ខខណ្ឌតម្រូវយ៉ាងច្បាស់លាស់ឱ្យគ្រប់មេធាវីបរទេសទាំងអស់នៅ អ.វ.ត.ក ផ្តល់ភ័ស្តុតាងបញ្ជាក់ឱ្យបានទៀងទាត់តាមពេលវេលាកំណត់អំពីសមាជិកភាពនៃគណៈមេធាវីជាតិនៅក្រៅប្រទេសកម្ពុជា។

សូមលោកចៅក្រមទទួលយកអនុស្សរណៈនេះដោយសេចក្តីគោរព។